ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០

# សេចក្តីប្រកាសព័ត៌មាន

## កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង

## ស្តីពី

## គម្រោងអាហារូបករណ៍ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស (JDS)

នាព្រឹកថ្ងៃច័ន្ទ ៩កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចុះហត្ថលេខា ដោយជោគជ័យ លើកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង សម្រាប់**គម្រោងអាហារូបករណ៍ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស** (JDS) ដែលមានទឹកប្រាក់សរុប **៣៤៨** លានយ៉េន (ប្រមាណជា **៣.២៣** លានដុល្លាអាមេរិក) ។

គម្រោងនេះមានគោលដៅដោះស្រាយនូវរាល់បញ្ហាប្រឈមក្នុងការអភិវឌ្ឍនៅប្រទេសកម្ពុជា ដោយគាំទ្រដល់មន្ត្រីរដ្ឋាភិបាលវ័យក្មេង ដែលរំពឹងថានឹងក្លាយជាអ្នកដឹកនាំក្នុងប្រទេសកម្ពុជា ដោយទទួលបានសញ្ញាបត្រអនុបណ្ឌិត ឬបណ្ឌិត ពីគ្រឹះស្ថានឧត្តមសិក្សានៅប្រទេសជប៉ុន ។ មន្ត្រីដែលគាំទ្រដោយគម្រោង JDS អាចប្រើប្រាស់ការសិក្សា បទពិសោធន៍ និងបណ្តាញធនធានមនុស្សតាមរយៈគម្រោងដើម្បីបង្កើត និងអនុវត្តផែនការណ៍អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ក្នុងប្រទេសកម្ពុជា ។

គម្រោង JDS បានចាប់ផ្តើមជ្រើសរើសបេក្ខជនក្នុងឆ្នាំ២០០០ និងបានបញ្ជូននិស្សិតជំនាន់ទីមួយក្នុងឆ្នាំ២០០១ ដូច្នេះឆ្នាំនេះគឺជាខួប២០ឆ្នាំនៃគម្រោង JDS ។ ចាប់តាំងពីគម្រោងបានចាប់ផ្តើម មាននិស្សិតសរុបចំនួន៤៧០ នាក់ហើយដែលទទួលបានអាហារូបករណ៍ពេញលេញ និងជំនួយផ្សេងៗទៀត ដើម្បីទទួលបានសញ្ញាបត្រអនុបណ្ឌិត និងបណ្ឌិតនៅប្រទេសជប៉ុន ។

គម្រោងនេះបានចូលរួមចំណែកយ៉ាងច្រើនក្នុងការអភិវឌ្ឍធនធានមនុស្ស ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រទេសកម្ពុជា ។ និស្សិត JDS ជាច្រើនបានទទួលមុខងារជាមន្ត្រីជាន់ខ្ពស់នៅតាមបណ្តាក្រសួងនានា ក្នុងប្រទេសកម្ពុជា ។ ម្យ៉ាងវិញទៀត គម្រោង JDS ជាស្ពានដើម្បីពង្រឹងទំនាក់ទំនងរវាងប្រទេស ប្រជាជន និងរដ្ឋាភិបាល ទាំងពីរឲ្យកាន់តែល្អប្រសើរឡើង ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖

- លោក **ធឿន វង់ឌី** មន្ត្រីកម្មវិធី នៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) តាមរយៈទូរសព្ទ ០២៣ ២១១ ៦៧៣/៤ ឬ តាមសារអេឡិចត្រូនិក Thoeun-vongdy@jica.go.jp ៕